# ប្រទេសកម្ពុជាដាក់អោយប្រើប្រាស់ប្រពន្ធ័ម៉ាស៊ីន ATM រួមក្នុងស្រុក

## *ធនាគារក្នុងស្រុកទាំង ៤ បានសហការគ្នាប្រើប្រាស់សេវាប្រពន្ធ័ម៉ាស៊ីន ATM រួមថ្មីមួយ*

**ប្រទេសកម្ពុជា ២៨ សីហា ២០០៨:** ធនាគារមេគង្គកម្ពុជា ធនាគារកាណាឌីយ៉ា ធនាគារសាជីវកម្ម សិង្ហបុរី និងធនាគារសហពាណិជ្ជ រួមជាមួយ VISA បានផ្សព្វផ្សាយការចេញនូវរចនាសម្ពន្ធ័ក្នុងការ បង់ប្រាក់ដំបូងក្នុងស្រុកនៅប្រទេស ដែលនេះគឺជាជំហានក្នុងការដាក់បញ្ចូលគ្នាជាលើកដំបូងនូវបណ្តាញ ATM នៃធនាគារក្នុងស្រុក។ ឆ្លើយតបទៅនឹងការរីកចំរើនយ៉ាងឆាប់រហ័សរបស់ប្រជាជាតិ អាស៊ីអាគ្នេយ៍ ប្រព័ន្ធ (Easy Cash) នឹងផ្តល់ជូននូវ ATM ចំនួន ៨៦ សំរាប់អតិថិជន ។

ប្រធានតំបន់របស់ VISA ទទួលបន្ទុកប្រទេសវៀតណាម កម្ពុជា និង ឡាវ លោកស្រី ទ្រឿង ម៉ិញ ហា បានមានប្រសាសន៍ថា VISA និង ធនាគារជាដៃគូបានធ្វើកិច្ចការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលប្រទេសកម្ពុជាក្នុងការអភិវឌ្ឍន៍ និងបង្កើតប្រព័ន្ធមួយដែលអាចផ្តល់ជូនសេវាកម្មធនាគារអេឡិចត្រូនិច (Electronic Banking Service-EBS) អោយសមស្របតាមការកើនឡើងរបស់បណ្តាញធនាគារដែលរីកដុះដាលយ៉ាងឆាប់រហ័សនៅក្នុងប្រទេស។

យើងមានជំនឿថាគំរោងថ្មីនេះ នឹងនាំមកនូវការផ្លាស់ប្តូរក្នុងប្រទេសកម្ពុជាដែលអាចជួយជំរុញប្រតិបត្តិការសេវាកម្មអេឡិចត្រូនិចសំរាប់ប្រជាជនកម្ពុជាហើយ និង ដើរតួនាទីយ៉ាងសំខាន់ដើម្បីផ្តល់តំលៃបន្ថែមលើគុណភាពសេវាកម្ម ដូចដែលគេបានដកពិសោធន៍គួរអោយកត់សំគាល់លើកំនើនការប្រើប្រាស់ម៉ាស៊ីន ATM។ លោកស្រី ម៉ិញ ហា បានបន្តទៀតថា ធនាគារបានធ្វើការអង្កេតតាមគ្រប់វិធីដែលអាចធ្វើទៅបានដើម្បីភ្ជាប់ប្រពន្ធ័របស់ខ្លួន រួមទាំងការបង្កើតឡើងនូវដៃគូទ្វេភាគីជាច្រើន និងលទ្ធភាពក្នុងការបង្កើតបណ្តាញមួយដោយខ្លួនឯង។

ធនាគារទាំងបួនបានយល់ស្របគ្នាថាដំណោះស្រាយដ៏មានប្រសិទ្ធិភាព និង យ៉ាងឆាប់ក្នុងការឆ្លើយតបទៅ នឹងតំរូវការគឺការភ្ជាប់បណ្តាញ ATM តាមរយះបណ្តាញ VISA។ ការសំរេចនេះត្រូវបានធ្វើឡើងផ្អែកលើមាត្រដ្ឋាន និង បច្ចេកវិទ្យានៃប្រពន្ធ័ VisaNet រួមជាមួយនិង ក្រុមជំនាញរបស់ Visa។

សេវាកម្មនេះគឺជាបណ្តាញក្នុងស្រុកតែមួយគត់ដើម្បីភ្ជាប់ការរួមបញ្ចូលគ្នារបស់ធនាគារទាំង ៤ តាមប្រព័ន្ធ អេឡិចត្រូនិច និង ផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការប្រើប្រាស់គណនីផ្ទាល់ខ្លួនពីម៉ាស៊ីន ATM មួយទៅមួយទៀត។

អតិថិជនធនាគារមិនមានឧបសគ្គក្នុងការប្រើប្រាស់ ATM ពីធនាគារមួយទៀតឡើយ នេះបើតាមប្រសាសន៍លោក ថេត វ៉ាណារ៉ា ប្រធានមណ្ឌលបណ្ណ័នៃធនាគារមេគង្គកម្ពុជា។

លោក Luis Chen អគ្គនាយករង ធនាគារ កាណាឌីយ៉ាបានមានប្រសាសន៍ថា ប្រព័ន្ធ VisaNet និង បង្កើនចំនួនម៉ាស៊ីន ATM ដែលផ្តល់ជូនដល់អតិថិជនយើង។ ជាការពិតអតិថិជនរបស់យើងឥឡូវអាចមានភាពងាយស្រួលក្នុងការប្រើប្រាស់ម៉ាស៊ីនអេឡិចត្រូនិច ATM ចំនួន ៨៦ជុំវិញប្រទេស ដែលក្នុងន័យនេះពួកគាត់អាចដកប្រាក់ និង គ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួនរបស់គាត់។ យើងមានគំរោងនឹងបង្កើនម៉ាស៊ីន ATM ចំនួន ១២៦ នៅក្រោម VisaNet នាមុនបំណាច់ឆ្នាំ ២០០៨នេះ។ ប្រព័ន្ធ VisaNet មានអត្ថប្រយោជន៍ដល់ហេដ្ឋារចនាសម្ព័ន្ធម៉ាស៊ីនអេឡិចត្រូនិចរបស់ធនាគារដែលមានស្រាប់។

ដោយរួមបញ្ចូលគ្នាក្រោមឈ្មោះ អ៊ីស៊ីកាស (Esay Cash) ធនាគារមិនចាំបាច់វិនិយោគបន្ថែមទៅលើម៉ាស៊ីន ATM បន្ថែមឬបន្ថែមភាគហ៊ុនរបស់ខ្លួនក្នុងទីផ្សារឡើយ។
លោក Diaz Kun, អគ្គនាយករងនៃធនាគារ សាជីវកម្មសិង្ហបូរី បានមានប្រសាសន៍ថាម៉ាស៊ីន ATM បានទទួលនូវភាពលេចធ្លោក្នុងនាមជាឧបករណ៍ សំរាប់ប្រតិបត្តិការនៅកម្ពុជា ហើយធនាគារបានបញ្ចេញម៉ាស៊ីន ATM បន្ថែមទៀតក្នុងការបង្កើនទំនាក់ទំនងរបស់គេ។ អត្ថប្រយោជន៏នៃការ ធ្វើការរួមបណ្តាញ ATM ជាមួយនិងធនាគារដ៏ទៃទៀតដែលរួមមានការបង្កើតឡើងបណ្តាញ ATM ដ៏ធំមួយនិងការចែករំលែកការប្រើប្រាស់ម៉ាស៊ីន ATM ជាមួយនិងប្រតិបត្តិការបន្ថែមទៀតក្នុងមួយថ្ងៃៗ។ បណ្តាញ ATM អ៊ីស៊ីកាសនឹងធ្វើអោយជីវិតកាន់តែងាយស្រួលឡើងសំរាប់អតិថិជនរបស់ធនាគារព្រោះអតិថិជនអាចប្រើប្រាស់ម៉ាស៊ីន ATM ជាច្រើនជុំវិញប្រទេស។

បណ្តាញ អ៊ីស៊ីកាស អាចធ្វើអោយវាកាន់តែងាយឡើងសំរាប់ប្រជាជនក្នុងការដកប្រាក់សុទ្ធ ពិនិត្យគណនីធនាគាររបស់ខ្លួនហើយគ្រប់គ្រងហិរញ្ញវត្ថុរបស់គាត់តាមរបៀបមួយដ៏ងាយស្រួលដែលមិនធ្លាប់មានពីមុនមក។
ប្រជាជន កម្ពុជាអាចប្រើសេវាកម្មធនាគារដែលងាយដូចជា តារាងសមតុល្យនិងការដកប្រាក់សុទ្ធនៅតាមបណ្តាញម៉ាស៊ីន ATM អ៊ីស៊ីកាស ណាមួយជុំវិញប្រទេស។
លោក (Yong Kah Wah) ប្រធានមណ្ឌលកាតនៃធនាគារសហពាណិជ្ជ UCB មានសេចក្តីរំភើបយ៉ាងខ្លាំងពេលដែលបានឃើញសេវាកម្មបណ្តាញ អ៊ីស៊ីកាស មានការរីកដុះដាលនៅប្រទេសកម្ពុជា។ អតិថិនជនសព្វថ្ងៃនេះគឺនៅតែបន្តស្វែងរកវិធីដែលកាន់តែងាយស្រួលក្នុងការ គ្រប់គ្រង និង ប្រើប្រាស់បណ្ណតណទានរបស់គាត់។ ការដាក់ចេញបណ្តាញ អ៊ីស៊ីកាស គឺកាន់តែមានដំណោះស្រាយដ៏ មាន ប្រសិទ្ធិភាពក្នុងការផ្តល់សេវាកម្មដល់អិតិថិជនរបស់ធានាគារសហពាណិជ្ជគ្រប់ៗគ្នា។

កំណត់ហេតុសំរាប់អ្នកកាសែត

១ VisaNet ជាប្រព័ន្ធសំរាប់ចាយវាយផ្នែកអេឡិចត្រូនិចដ៏ធំមួយរបស់ពិភពលោកដែលតភ្ជាប់ស្ថាប័នហិរញ្ញវត្ថុចំនួន ១៦ ៦00 និងមានកាតច្រើនជាង ១.៦កោដដល់ពាណិជ្ជករជាង ២៩លាន និង ១.២ លាន ATM ជុំវិញពិភពលោក។ ប្រព័ន្ធ VisaNetមានសមត្ថភាពក្នុងការដំណើរការជាង ១២ 000 ប្រតិបត្តការក្នុងមួយវិនាទី។
២ ដោយផ្អែកទៅលើស្ថាបត្យកម្មបែប Scalable និង Modular, Visanetមានលទ្ធភាពជំរុញដល់ការពង្រាយនូវការផ្តល់តំលៃបន្ថែមដល់ការផ្តល់គុណភាពសេវាកម្មក៏ដូចធ្វើអោយមានការរីកចំរើនលើបច្ចេកវិទ្យា។
Visa សំរួលដល់ការចាយវាយផ្នែកអេឡិចត្រូនិចទូទាំងពិភពលោកតាមរយៈប្រព័ន្ធផ្នែកអេឡិចត្រូនិចទៅលើប្រតិបិត្តតការសេវាកម្ម និង ទំនិញ។ ផលិតផលរបស់ Visa រួមមាន Consumer Credit, Debit, Prepaid និង Commercial ដែលផ្តល់អោយតាមរយៈ Visa, Visa Electron, Interlink និង Plus។ Visa/Plus ត្រូវបានទទួលស្គាល់ទូទាំងពិភពលោកថាជាប្រព័ន្ធ ATMដែលធំជាងគេ ក្នុងពិភពលោកដែលផ្តលនូវ ការដកសាច់ប្រាក់ជារូបិវត្ថុជាតិជាង ១៧0 ប្រទេស។